# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# <u>កិច្ចសន្យាព្រមព្រៀងជួលដី</u>

**កិច្ចព្រមព្រៀងជួលនេះ ត្រូវបានធ្វើឡើងរវាងៈ**

១- លោក.............................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ.............................................. និងភរិយាឈ្មោះ ..........................................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.............................................. មានអាស័យដ្ឋានលេខ ........................ផ្លូវលេខ......................សង្កាត់ ..........................................ខណ្ឌ..........................................ខេត្ត.......................................... ជាម្ចាស់ដី ដែលមានទីតាំង ស្ថិតនៅ.................................................................................................................................... ...................................................................................(ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី"ក"**) ។

**និង**

២- លោក ..........................................ភេទ.................
កើតនៅថ្ងៃទី..............ខែ..............ឆ្នាំ.................កាន់លិខិតឆ្លងដែនលេខ..........................................មានអាស័យដ្ឋានលេខ ................. ផ្លូវ...............សង្កាត់ ..........................................ខណ្ឌ.......................................... ខេត្ត.............................................. ជាអ្នកជួលដី (ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី"ខ"**) ។

**ភាគី"ក" និងភាគី"ខ" បានព្រមព្រៀងគ្នាតាមប្រការ និងលក្ខខណ្ឌដូចតទៅៈ**

**<u>ប្រការ១ៈ</u> កិច្ចព្រមព្រៀងជួល**

**ភាគី"ក"** យល់ព្រមជួលដី អោយ **ភាគី"ខ"** ក្នុងរយៈពេល..............................ឆ្នាំ គិតចាប់ពីថ្ងៃទី ...................... .ខែ ..................ឆ្នាំ ..................រហូតដល់ថ្ងៃទី..................ខែ..................ឆ្នាំ..................(តទៅនេះហៅកាត់ថា **"រយៈពេលជួល"**) ។

**<u>ប្រការ២ៈ</u> ថ្លៃឈ្នួលប្រចាំខែ**

ថ្លៃឈ្នួលប្រចាំខែគឺ ..............................USD (.....................................ដុល្លារអាមេរិកក្នុងមួយខែ) ក្នុងរយៈពេលជួល ហៅថា ប្រាក់ឈ្នួល **ភាគី"ខ"** ត្រូវបង់ប្រាក់ឈ្នួលទៅអោយ **ភាគី"ក"** នៃដើមខែនីមួយៗនៅរៀងរាល់ខែដោយចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៧ នៃដើមខែនីមួយៗ ។ ប្រសិនបើ **ភាគី"ខ"** ខកខានមិនបានបង់ប្រាក់ឈ្នួលទៅតាមកិច្ចសន្យានេះទេ ប្រាក់កក់ និងត្រូវទុកជាអសារបង់ ហើយចំពោះកិច្ចសន្យាជួលដី ត្រូវទុកជាមោឃៈដោយស្វ័យប្រវត្តិ ។

**<u>ប្រការ៣:</u> ប្រាក់កក់**

**ភាគី "ខ"** បានយល់ព្រមបង់ប្រាក់កក់ជូនទៅ **ភាគី "ក"** ចំនួន .....................USD (.......................................ដុល្លារអាមេរិក) ស្មើនឹងប្រាក់ឈ្នួលប្រចាំខែ ...........ខែ ចាប់ពីពេលនេះតទៅហៅកាត់ថា ប្រាក់កក់ ប្រសិនបើ **ភាគី "ខ"** បញ្ចប់កិច្ចសន្យាជួលមុនកាលកំណត់ជួលនេះ ប្រាក់កក់ត្រូវទុកជាអសារបង់របស់ **ភាគី "ក"** ។ ប៉ុន្តែក្រោយពេលផុតកំណត់រយៈពេលជួល **ភាគី "ក"** ត្រូវបង្វិលប្រាក់កក់ជូន **ភាគី "ខ"** វិញគ្រប់ចំនួន ។

**<u>ប្រការ៤:</u> ការលក់ដី ឬផ្ទេរ**

ប្រសិនបើ **ភាគី "ក"** ធ្វើការលក់ដីខាងលើនេះទៅអោយភាគីណា ឬ ក្រុមហ៊ុនណាមួយផ្សេងនោះ **ភាគី "ក"** និងម្ចាស់កម្មសិទ្ធិថ្មីត្រូវរក្សា និងគោរពតាមគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាជួលនៅដដែល រហូតដល់ពេលផុតកំណត់នៃកិច្ចសន្យាជួល ។ **ភាគី "ខ"** មិនត្រូវបានអនុញ្ញាតិអោយធ្វើការផ្ទេរ ឬ ជួលបន្តដីនេះទៅអោយភាគីទី៣ បានឡើយ ។ (អាចជួលបាន) ត្រូវតែជូនដំណឹង និងមានការឯកភាពយល់ព្រមពីសំណាក់ **ភាគី "ក"** ជាមុនសិន ។

**<u>ប្រការ៥:</u> លើប្រាក់ពន្ធ ទឹក ភ្លើង និងសេវាកម្មផ្សេងៗ**

**ភាគី "ខ"** ត្រូវទទួលខុសត្រូវថ្លៃប្រើប្រាស់ ទឹក ភ្លើងអគ្គិសនី សំរាម ទូរស័ព្ទ ទូរទស្សន៍ខ្សែកាប និងការបង់ពន្ធធ្វើអាជីវកម្មនៅលើដីនេះ ។ល។ តាមច្បាប់រដ្ឋដែលបានកំណត់អោយបង់ និងតាមវិក័យប័ត្រដែលក្រុមហ៊ុននីមួយៗបានផ្តល់អោយ ក្នុងកំឡុងពេលនៅកិច្ចសន្យាជួល ។ ប្រសិនបើវិក័យប័ត្រដែលមិនបានបង់ និងត្រូវកាត់យកពីប្រាក់កក់នៅពេលផុតកំណត់រយៈពេលជួល ។

**<u>ប្រការ៦:</u> សុវត្ថិភាពសង្គម និងការថែទាំ**

**ភាគី "ខ"** ត្រូវជួយថែទាំដីនេះក្នុងលក្ខណៈល្អត្រឹមត្រូវ និងមានអនាម័យក្នុងកំឡុងពេលជួល ហើយ **ភាគី "ខ"** មិនត្រូវប្រើប្រាស់ដីនេះ ដើម្បីធ្វើសកម្មភាពផ្ទុយ និងច្បាប់ ឬខុសច្បាប់ផ្សេងៗ ឡើយ ដូចជា: ជួញដូរគ្រឿងញៀន, បើកបន, ឬផ្ទុកអាវុធ ។ល។ ហើយត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះសកម្មភាពរបស់ខ្លួនផ្ទាល់ ។ ករណីអគ្គិភ័យ និងការបង្កជំលោះជាមួយអ្នកជិតខាង និងការបាត់បង់ដែលបង្កឡើងដោយការធ្វេសប្រហែសរបស់ **ភាគី "ខ"** នោះ ជាបន្ទុករបស់ **ភាគី "ខ"** ក្នុងការសងការខូចខាត ។

**<u>ប្រការ៧:</u> ការយល់អំពីកិច្ចសន្យាជួល**

កិច្ចសន្យានេះត្រូវធ្វើឡើងចំនួន ០៣ច្បាប់ ដែលមានខ្លឹមសារ និងសុពលភាពស្មើគ្នា ។ ភាគីទាំងពីរបាន អានគ្រប់ខ្លឹមសារ និងលក្ខខណ្ឌក្នុងកិច្ចសន្យានេះ ហើយភាគីនីមួយៗ ត្រូវគោរពគ្រប់ប្រការតាម លក្ខខណ្ឌនៃកិច្ចសន្យានេះ ។ ប្រសិនបើភាគីណាមួយប្រព្រឹត្តបទល្មើស និងកិច្ចសន្យានេះ ភាគីនោះត្រូវ ទទួលខុសត្រូវចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចសន្យានេះ ភាគីនីមួយៗរក្សាទុក ម្នាក់មួយច្បាប់ និងសាក្សីមួយច្បាប់ និងយល់ព្រមផ្តិតមេដៃស្តាំទុកជាភស្តុតាង ។

ធ្វើនៅ, ថ្ងៃទី .............. ខែ.................... ឆ្នាំ ........................

**ស្នាមមេដៃភាគី "ខ"** **សាក្សី** **ស្នាមមេដៃភាគី "ក"**